# អនុក្រឹត្យ

# ស្តីពីវិធាន និងនីតិ
# វិធីនៃអនុបយោគ
# ទ្រព្យសម្បត្តិ
# សាធារណៈរបស់រដ្ឋ
# និងរបស់នីតិបុគ្គល
# សាធារណៈ

# ២០០៦

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ទិដ្ឋាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលរចនាសម្ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៦

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសំរាប់គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ ទាក់ទងនឹង ÷

- ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ
- ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
- ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មានដូចខាងក្រោម ÷

១- រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងរបស់នីតិបុគ្គលសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការលក់ ការដូរ និងការជួល នូវទ្រព្យសម្បត្តិរបស់រដ្ឋ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការដូរចលនទ្រព្យ និងអចលនទ្រព្យ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ជូនរាជរដ្ឋាភិបាល ។

២- ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកំពុងកាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ជាអាជ្ញាធរកាន់កាប់ប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋ

នៅក្នុងន័យនៃអនុក្រឹត្យនេះ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានសមត្ថកិច្ចត្រឹមតែប្រើប្រាស់ ថែរក្សា និងស្នើសុំ លក់ ដូរ ឬជួល ។

៣- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ ត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ អាចត្រូវបានលក់ ដូរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងទៀតបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការលក់ ការដូរ និងការជួលទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុក្រឹត្យនេះ។ ចំណែកឯលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើសម្បទានទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៣.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ទ្រព្យសម្បត្តិទាំងនេះអាចជាចលនទ្រព្យ និងអចលនទ្រព្យ។ ទ្រព្យសម្បត្តិរបស់រដ្ឋ សំដៅលើទ្រព្យសម្បត្តិទាំងឡាយ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយ ដែលរដ្ឋប្រគល់ទៅឱ្យនីតិបុគ្គលសាធារណៈដទៃទៀត កាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្ម។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺមានទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ ក្រៅពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចបានកំណត់ក្នុងមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ព្រមទាំងមាត្រា ១២ និងមាត្រា ១៥ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១។

**មាត្រា ៤.-**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់ រួមទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការជួល ការលក់ និងការដូរបាន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀត មិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ឬការផ្ទេរកម្មសិទ្ធិណាមួយបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនេះ អាចជាកម្មវត្ថុនៃការជួលបានតែក្នុងលក្ខខណ្ឌ និងនីតិវិធីដែលមានបញ្ញត្តិនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ២

## ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ

**មាត្រា ៥.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានចលនទ្រព្យ និងអចលនទ្រព្យ ទាំងអស់ដែលស្ថិតនៅក្រោមអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជា ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា ៦.-**

ការធ្វើបញ្ជីសារពើភ័ណ្ឌ ចែកចេញជាបួនថ្នាក់ រួមមាន ÷

១- ថ្នាក់កណ្តាល ឬថ្នាក់ក្រសួង ស្ថាប័ន

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋដែលកាន់កាប់ដោយក្រសួង ស្ថាប័ន ត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ថ្នាក់ដឹកនាំក្រសួងស្ថាប័ន ជាប្រធាន
- ប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ ដែលបានរៀបចំរួច។

២- ថ្នាក់មន្ទីរជំនាញតាមខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ប្រធានមន្ទីរជំនាញសាមីដែលទទួលខុសត្រូវអង្គភាពប្រើប្រាស់ ជាប្រធាន
- ប្រធានការិយាល័យប្រើប្រាស់នៃមន្ទីរជំនាញ ជាសមាជិក
- ប្រធានការិយាល័យប្រើប្រាស់ តាមស្រុកខណ្ឌ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវ លើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត ក្រុង។

៣- ថ្នាក់ខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង រួមមានសមាជិកដូចខាងក្រោម ÷

ក. សាលាខេត្ត ក្រុង :

- នាយខុទ្ទកាល័យ ឬប្រធានក្រុមហិរញ្ញវត្ថុ ជាប្រធាន
- គ្រប់ប្រធានការិយាល័យផ្ទៃក្នុងរបស់សាលាខេត្ត ក្រុង ជាសមាជិក ។

ខ. សាលាស្រុក ខណ្ឌ :

- អភិបាលស្រុក ខណ្ឌ ជាប្រធាន
- ប្រធានការិយាល័យផ្ទៃក្នុង· ជាសមាជិក
- មេឃុំ- ចៅសង្កាត់ ជាសមាជិក ។"

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត ក្រុង ។

៤- ថ្នាក់នីតិបុគ្គលសាធារណៈដទៃទៀត

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតឡើងដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិក ដូចខាងក្រោម ÷

- ប្រធានអង្គភាព ជាប្រធាន
- ប្រធានផ្នែកជំនាញពាក់ព័ន្ធ ជាសមាជិក

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ ដែលបានរៀបចំរួច ។

**មាត្រា ៧.-**

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកជំរុញ និងណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ឱ្យរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលមានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ យ៉ាងយូរនៅចុងត្រីមាសទី ១ នៃឆ្នាំបន្ទាប់ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសំរេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរបស់រដ្ឋចូលក្នុងបញ្ជីសារពើភ័ណ្ឌ ។

រាល់បញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួចរាល់ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវផ្តល់ចំនួនពីរច្បាប់ ជូន ដល់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីតំកល់ទុក និងតាមដាន ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៣
## ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
## ផ្នែកទី ១
## ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

### មាត្រា ៨.-

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យ-សម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

### មាត្រា ៩.-

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួន ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ។

**មាត្រា ១០.-**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវរៀបចំធ្វើឡើង ក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិដែលជាការជួល អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសំរេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចជាមុនពីប្រមុខរាជរដ្ឋាភិបាល។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចា ពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ១១.-**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់។

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

**មាត្រា ១២.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គល កំរិតជាតិ ឬអន្តរជាតិ ចាប់ពី ២ ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវជួល។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១- ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ

២- ប្រកួតប្រជែងដោយផ្ទាល់មាត់ជាលក្ខណៈជាតិ ឬអន្តរជាតិ។

**មាត្រា ១៣.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១- ការដេញថ្លៃមិនទទួលបានលទ្ធផល

២- លក្ខណៈពិសេសនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលតំរូវឱ្យអ្នកជួលត្រូវបំពេញបន្ថែមនូវលក្ខខណ្ឌចាំបាច់ផ្សេងៗទៀត។

៣- មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំជួលតែមួយ។

**មាត្រា ១៤ ._**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការជាស្ថាពរ ដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ មានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាជួល ដើម្បីរៀបចំនូវសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចបន្តសាជាថ្មីបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃបានមិនព្រមចរចា ពិភាក្សា រៀបចំកិច្ចសន្យាជួល តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យាត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសំរួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ យ៉ាងយូរ ក្រោយពីទទួលបានពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ។

កិច្ចសន្យាត្រូវចែងអំពីលក្ខខណ្ឌចាំបាច់ដែលមានជាអាទិ៍ ÷

១- ការកំណត់ថ្លៃឈ្នួល និងការបង់ថ្លៃឈ្នួល ដោយគិតតាមខែ ត្រីមាស ឬ ឆ្នាំ តាមការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ។

២- ក្នុងករណីបង់ថ្លៃឈ្នួលយឺតយ៉ាវ អ្នកទទួលជួលត្រូវទទួលការពិន័យ ២ (ពីរ) ភាគរយក្នុងមួយខែលើថ្លៃឈ្នួល ដែលត្រូវបង់តាមខែ ត្រីមាស ឬ ឆ្នាំ ចាប់ពីរយៈពេល ៦០ (ហុកសិប) ថ្ងៃ ក្រោយការកំណត់តទៅ។ ប្រាក់ពិន័យនេះ ត្រូវគណនាតាមរូបមន្តការប្រាក់សមាស។

៣- ក្នុងករណីខកខានបង់ថ្លៃឈ្នួលក្នុងរយៈពេលសរុប ៦ (ប្រាំមួយ) ខែ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវលុបកិច្ចសន្យា និងត្រូវអនុវត្តតាមផ្លូវច្បាប់ជាធរមាន បន្ទាប់ពីមានការយល់ព្រមពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ ក្នុងករណីនេះ ប្រសិនបើអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមិនអាចអនុវត្តបានទេ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនឹងចាត់វិធានការ ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីលុបកិច្ចសន្យា និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

កិច្ចសន្យាជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយណា ដែលមិនគោរពតាមនីតិវិធី និងមិនចែងនូវលក្ខខណ្ឌចាំបាច់ដូចខាងលើនេះ ត្រូវចាត់ទុកជាមោឃៈ។

## ផ្នែកទី ២

## ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

**មាត្រា ១៥.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិសាធារណៈនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា ១៦.-**

ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម ÷

១- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនត្រូវធ្វើឱ្យមានការកែប្រែទិសដៅនៃការប្រើប្រាស់ ឬធ្វើឱ្យមានការខូចខាតដល់ទ្រព្យសម្បត្តិទាំងនោះឡើយ។

២- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនត្រូវមានការប៉ះពាល់ ឬធ្វើឱ្យផ្លាស់ប្តូរដល់មុខងារបំរើសេវាសាធារណៈរបស់ទ្រព្យសម្បត្តិទាំងនោះឡើយ។

**មាត្រា ១៧.-**

ក្រោយពីទទួលបានការអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចរៀបចំដំណើរការនៃការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនេះ ទៅតាមនីតិវិធីដូចដែលកំណត់នៅក្នុងផ្នែកទី២ នៃជំពូកនេះ ។

**មាត្រា ១៨.-**

កិច្ចសន្យាជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចមានរយៈពេលលើសពី ១៥ (ដប់ប្រាំ) ឆ្នាំឡើយ។ កិច្ចសន្យានេះធ្វើឡើងក្រោមរូបភាពជាលិខិតអនុញ្ញាតកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលមានលក្ខណៈជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបានគ្រប់ពេលវេលា ក្នុងបំណងការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងបំរើប្រយោជន៍សាធារណៈ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានភារកិច្ចរៀបចំសៀវភៅបន្ទុកដែលកំណត់អំពីលក្ខខណ្ឌផ្សេងៗនៃការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ។

## ផ្នែកទី ៣
## ការកែសម្រួលបំពេញបន្ថែមលើកិច្ចសន្យាជួល និងការបង់ចំណូល

**មាត្រា ១៩.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលជាភាគីនៃកិច្ចសន្យាជួលមានរយៈពេល ៩ (ប្រាំបួន) ខែ ដើម្បីពិនិត្យ និងធ្វើការកែសម្រួលលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរបស់រដ្ឋទាំងឡាយ ដែលបានធ្វើឡើងមុនអនុក្រឹត្យនេះចូលជាធរមាន ដោយរៀបចំបន្ថែមនូវល័ក្ខខ័ណ្ឌចាំបាច់ដូចដែលមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុន នៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលកំពុងស្ថិតក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ទាំងអចលនទ្រព្យ និងចលនទ្រព្យ ។

**មាត្រា ២២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកលើកសំណើសុំលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ហើយត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋនេះ ដែលជាកម្មវត្ថុនៃការលក់ទៅឱ្យភាគីម្ខាងទៀត ដោយភ្ជាប់ឯកសារពាក់ព័ន្ធទាំងអស់នេះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ២៣.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួនជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះ ត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យ សម្បត្តិរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ។

**មាត្រា ២៥.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវរៀបចំធ្វើឡើងក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ដូចករណីនៃការជួលដែរ ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។ ក្នុងករណីចាំបាច់ត្រូវមានការសម្រេចជាមុនពីរាជរដ្ឋាភិបាល ។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៦.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គលកើតជាតិ ឬអន្តរជាតិ ចាប់ពី ២ (ពីរ) ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវលក់ ។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១-ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

២-ប្រកួតប្រជែងដោយផ្ទាល់មាត់ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

**មាត្រា ២៧.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១-បើការដេញថ្លៃមិនទទួលបានលទ្ធផល ។

២-មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំទិញតែមួយ ។

៣-អ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះស្នើសុំទិញពីរដ្ឋ ក្នុងករណីអ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះបានចំណាចទុនវិនិយោគបានយ៉ាងតិចចំនួន ៣០ (សាមសិប)ភាគរយនៃគម្រោងវិនិយោគ ឬក្នុងករណីដែលរដ្ឋបានផ្តល់មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធដែលមានរួចស្រេច ហើយគម្រោងនោះបានដំណើរការរយៈពេល ១(មួយ) ឆ្នាំ យ៉ាងតិច ។

**មាត្រា ២៨.-**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលទទួលស្គាល់ជាផ្លូវការជាស្ថាពរពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាលហើយនោះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ សម្រាប់ពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាលក់-ទិញ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀត ដែលរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងជាការចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃមិនព្រមចរចាពិភាក្សារៀបចំកិច្ចសន្យាទិញ-លក់តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសចូលថវិការដ្ឋ ។

បន្ទាប់ពីមានការព្រមព្រៀងលើរាល់លក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យា រវាងភាគីកិច្ចសន្យា និងក្រោយពីទទួលបានការពិនិត្យ និងកែសម្រួលពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋរួចរាល់ ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា ។

**មាត្រា ២៩.-**

ចំណូលដែលបានមកពីការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣០.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនភាគីឯកជនបាន អាចធ្វើទៅបានលុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត តាមកំណត់ច្បាប់ ។

## ជំពូកទី ៥
## ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ៣១.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺជាការផ្ទេរកម្មសិទ្ធិទៅវិញទៅមករវាងភាគីឯកជន និងភាគីរដ្ឋ ។

ការដូរធ្វើឡើងក្នុងគោលបំណងដោះស្រាយទីកន្លែងបំពេញការងារ រៀបចំតំបន់រដ្ឋបាលឱ្យបានសមស្របតាមតម្រូវការជាក់ស្តែង និងតាមនិន្នាការអភិវឌ្ឍន៍ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចស្នើដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយ ដែលរួមមានចលនទ្រព្យ និងអចលនទ្រព្យ ដើម្បីបានមកវិញនូវទ្រព្យសម្បត្តិថ្មីសមស្រប ដែលផ្តល់ឱ្យដោយភាគីឯកជន ។

**មាត្រា ៣២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការដូរជាមួយនឹងទ្រព្យសម្បត្តិដែលផ្តល់ដោយឯកជន មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៣៣.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយមានការចូលរួមពីតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរនោះ ស្របតាមគោលការណ៍បច្ចេកទេស និងតម្លៃទីផ្សារ ។

**មាត្រា ៣៥.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាមួយនឹងទ្រព្យសម្បត្តិរបស់ភាគីឯកជន ត្រូវប្រព្រឹត្តិតាមរូបភាពដេញថ្លៃជាសាធារណៈ ឬចរចាពិគ្រោះថ្លៃ ទៅតាមនីតិវិធីដូចដែលមានចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃអនុក្រឹត្យនេះ។

ភាគីឯកជនដែលចូលរួមដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ត្រូវមានទ្រព្យសម្បត្តិសមស្រប ដើម្បីជាថ្នូរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ល័ក្ខខ័ណ្ឌ និងការទូរទាត់តម្លៃនៃការដូរ ត្រូវកំណត់ឡើងដោយសៀវភៅបន្ទុកមួយ ដែលត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាជ្ញាធរនេះត្រូវផ្ញើសៀវភៅបន្ទុកនោះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា ៣៦.-**

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវពិនិត្យផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចារពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការស្ថាពរដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាដូរ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃបាន មិនព្រមចរចាពិភាក្សា រៀបចំកិច្ចសន្យាដូរតាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការរដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យា ត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសម្រួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ។

**មាត្រា ៣៨.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនឯកជន អាចធ្វើទៅបាន លុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត ។

**មាត្រា ៣៩.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ
## ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ

**មាត្រា ៤០.-**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវធ្វើឡើងតាមគោលការណ៍ និងបទប្បញ្ញត្តិដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៤១.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានតួនាទីធ្វើការអង្កេតជាសាធារណៈ និងធ្វើរបាយការណ៍បញ្ជាក់អំពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបានបាត់បង់លក្ខណៈសម្បត្តិរបស់ខ្លួន ក្នុងការបម្រើផលប្រយោជន៍សាធារណៈ តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយស្នើសុំធ្វើអនុបយោគ ដោយមានភ្ជាប់សំណុំឯកសារទាំងអស់

មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលសម្រេច តាមរយៈអនុក្រឹត្យ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ៤២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៤៣
- ឯកសារ- កាលប្បវត្តិ